ខែ ធ្នូ ឆ្នាំ ២០២០

# ឯកសារគោលនយោបាយស្តីពីការវិនិយោគឆ្លងដែនលើវិស័យកសិកម្ម


វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia

FAIR FINANCE CAMBODIA
A MEMBER OF FAIR FINANCE ASIA



Supported by

ស៊ុយអែត
Sverige

Diakonia
People Change the World

OXFAM

# មាតិកានុក្រម


សេចក្តីសង្ខេបរួម ... 1

១ សាវតារ ... 4

២ វិធីសាស្ត្រ ... 5

៣ របកគំហើញសំខាន់ៗ និងការវិភាគ ... 6

៣.១ សេចក្តីអធិប្បាយអំពីបញ្ហា ... 6

៣.២ វិសាលភាពនៃអនុសាសន៍ ... 7

៤ អនុសាសន៍ ... 7

៤.១ ការកសាងសមត្ថភាព ... 7

៤.១.១ សេចក្តីផ្តើម ... 7

៤.១.២ វគ្គបណ្តុះបណ្តាល និងយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន ... 8

៤.២ និយ័តកម្ម ... 9

៤.២.១ សេចក្តីផ្តើម ... 9

៤.២.២ បង្កើតយុទ្ធសាស្ត្រវិស័យមួយ និងវេទិកាចូលរួម ... 10

៤.២.៣ បង្កើតឧបករណ៍ដើម្បីគ្រប់គ្រងអនុលោមភាព និងការសន្ទនាភាគីពាក់ព័ន្ធ ... 11

៤.៣ ការតាមដាន និងការបញ្ចេញព័ត៌មាន ... 11

៤.៣.១ សេចក្តីផ្តើម ... 11

៤.៣.២ គ្រឹះស្ថានហិរញ្ញវត្ថុរាយការណ៍អំពីយុទ្ធសាស្ត្រនិរន្តរភាព ... 13

៤.៣.៣ ផ្តល់ទម្រង់គំរូរួមសម្រាប់ការរាយការណ៍ ... 13

© **វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា** (THE NGO FORUM ON CAMBODIA)

របាយការណ៍នេះត្រូវបានរៀបចំឡើង, បោះពុម្ព, និងគាំទ្រមូលនិធិដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពី កម្ពុជា។ របាយការណ៍នេះត្រូវបានរក្សាសិទ្ធិគ្រប់យ៉ាង។ បុគ្គល ទីភ្នាក់ងារ និងស្ថាប័ននានាដែលមានបំណងក្នុងការបោះពុម្ពផ្សាយឡើងវិញ ត្រូវទាក់ទងជាមួយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា តាមអាសយដ្ឋានដូចខាងក្រោម៖

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា** (THE NGO FORUM ON CAMBODIA)
ផ្ទះលេខ #៩-១១, ផ្លូវ ៤៧៦, សង្កាត់ទួលទំពូងទី១, រាជធានីភ្នំពេញ, ប្រទេសកម្ពុជា
ទូរស័ព្ទ៖ ៨៥៥ (០) ២៣ ២១៤ ៤២៩
www.ngoforum.org.kh

***សេចក្តីបញ្ជាក់***
*គំនិត និងទស្សនៈដែលបានបញ្ចេញនិងលើកឡើងនៅក្នុងរបាយការណ៍នេះ មិនតំណាងឱ្យតួនាទី និងតម្លៃស្នូលរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (THE NGO FORUM ON CAMBODIA) នោះឡើយ។ គំនិត និងទស្សនៈទាំងនេះគ្រាន់តែបញ្ជាក់ពីការគាំទ្រសេចក្តីសំអាង និងការសន្និដ្ឋានរបស់អ្នកស្រាវជ្រាវតែប៉ុណ្ណោះ។*

## សេចក្ដីសង្ខេបរួម

ឯកសារគោលនយោបាយជាបន្តទៅនេះ គឺជាសេចក្ដីដកស្រង់ពីរបាយការណ៍ស្រាវជ្រាវអំពីការវិនិយោគ ដែនលើវិស័យកសិកម្មនៅកម្ពុជា។ ឯកសារនេះ មានបំណងផ្ដល់ខ្លឹមសារសម្រាប់ការពិភាក្សាអំពីការកែទម្រង់អនាគតទាក់ទិននឹងវិស័យហិរញ្ញវត្ថុកម្ពុជា ជាពិសេសការជំរុញហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព។ តាមរយៈការស្រាវជ្រាវឯកសាររបស់យើង យើងបានសង្កត់ធ្ងន់លើកំណើនភាពសមស្របនៃហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព ជាទស្សនទានបែបនវានុវត្តន៍មួយនៃការអភិវឌ្ឍអន្តរជាតិ រួមទាំងនៅកម្ពុជា។

អនុសាសន៍ទាំងឡាយ ដែលនៅក្នុងនោះ អនុសាសន៍មួយចំនួនជំរុញល័ក្ខខ័ណ្ឌតម្រូវផ្លូវច្បាប់កាន់តែតឹងរ៉ឹង និងការបង្កើតវគ្គបណ្ដុះបណ្ដាលសម្រាប់អ្នកប្រតិបត្តិការងារវិស័យហិរញ្ញវត្ថុ ផ្ដោតលើវិស័យបីដូចជា៖ ការលើកកម្ពស់ទុនមនុស្សតាមរយៈគំនិតផ្ដួចផ្ដើមកសាងសមត្ថភាព កំណែទម្រង់និយ័តកម្ម និងល័ក្ខខ័ណ្ឌតម្រូវខាងតម្លាភាព។ ខ្លឹមសារនៃអនុសាសន៍ទាំងនេះ ត្រូវបានរៀបចំតាមរបកគំហើញពីរបាយការណ៍ស្រាវជ្រាវ ដែលបានកំណត់ចន្លោះប្រហោងបីសំខាន់ៗនៅក្នុងនិរន្តរភាពបច្ចុប្បន្ននៃវិស័យហិរញ្ញវត្ថុកម្ពុជា។

ចន្លោះប្រហោងទាំងនេះ រួមមានកង្វះការយល់ដឹងនៅក្នុងចំណោមអ្នកប្រតិបត្តិនៅក្នុងវិស័យហិរញ្ញវត្ថុ ទាក់ទិននឹងទស្សនទាន និងផលជះនៃហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព ការបង្ខំអនុវត្តច្បាប់ខ្សោយនៃក្របខ័ណ្ឌនិយ័តកម្ម និងកង្វះល័ក្ខខ័ណ្ឌតម្រូវរួមមួយសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុទាក់ទិននឹងការបញ្ចេញព័ត៌មានស្ដីពីគំនិតផ្ដួចផ្ដើមប្រកបដោយនិរន្តរភាព។

ដោយអនុវត្តអនុសាសន៍ទាំងនេះ ចន្លោះប្រហោងនៅក្នុងវិស័យទាំងបីនេះ ប្រហែលជាអាចត្រូវបានបំពេញ។ យើងព្យាករណ៍ថាវិស័យហិរញ្ញវត្ថុកម្ពុជានឹងទទួលបានអត្ថប្រយោជន៍មួយចំនួន រួមមានកំណើនកម្រិតនៃទំនុកចិត្តក្នុងចំណោមភាគីពាក់ព័ន្ធ និងសមត្ថភាពកាន់តែច្រើននៅក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុក្នុងការកែប្រែកិច្ចប្រតិបត្តិការរបស់ពួកគេទៅជាការប្រតិបត្តិកាន់តែមាននិរន្តរភាព។

## ១ សាវតារ

ទោះបីជាមានអត្រាកំណើនសេដ្ឋកិច្ចថិតថេរក្ដី ក៏កិច្ចដំណើរការនៃការអភិវឌ្ឍកម្ពុជាមិនមែនសុទ្ធតែមានលក្ខណៈរលូននោះទេ។ នៅក្នុងវិស័យកសិកម្ម ដែលមានវត្តមានសម្បទានដីសេដ្ឋកិច្ចល្វឹងល្វើយ និងការវិនិយោគបរទេសច្រើន ការចោទប្រកាន់ក្នុងបណ្ដាឆ្នាំថ្មីៗបានផ្ដោតលើកិច្ចប្រតិបត្តិការនៃក្រុមហ៊ុនកសិធុរកិច្ច ជាពិសេស វិនិយោគិនបរទេស ទាក់ទិននឹងការគោរពរបស់ពួកគេចំពោះសហគមន៍មូលដ្ឋាន និងការកាន់កាប់ដី។

នៅក្នុងករណីផ្សព្វផ្សាយទូលាយមួយ សហគ្រាសកសិធុរកិច្ចវៀតណាមមួយដែលប្រតិបត្តិការនៅកម្ពុជា ពោលគឺក្រុមហ៊ុន Hoang Anh Gia Lai បានពាក់ព័ន្ធនៅក្នុងការឆ្ការដីដ៏ចម្រូងចម្រាស់មួយ ដែលបណ្ដាលឲ្យមានកំហឹងពីសហគមន៍មូលដ្ឋាន។ បណ្ដឹងរបស់សហគមន៍ទាំងនេះ ត្រូវបានដាក់ជូនអាជ្ញាធរជាន់ខ្ពស់ពីរបីដង រួមមានការិយាល័យទទួលបណ្ដឹងពលរដ្ឋ (ombudsman) នៃ

អង្គការអភិវឌ្ឍន៍អន្តរជាតិមួយ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)។ បណ្ដឹងទាំងនេះ ផ្ដោតមិនត្រឹមតែលើការមិនគោរពសិទ្ធិដីធ្លី និងសិទ្ធិកាន់កាប់ដោយសហគ្រាសធ្វើប្រតិបត្តិការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើការពាក់ព័ន្ធរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ក្នុងការផ្ដល់កម្ចីដល់សហគ្រាសខាងលើតាមរយៈធនាគារអន្តរការីទៀតផង។ ការពាក់ព័ន្ធនេះ ចោទជាសំណួរអំពីការប្ដេជ្ញារបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ក្នុងការជំរុញការអនុវត្តការវិនិយោគប្រកបដោយនិរន្តរភាព។

ករណីនេះលើកឡើងនូវបញ្ហានៃទំនាក់ទំនងនៅកម្ពុជារវាងតួនាទីនៃហិរញ្ញវត្ថុ និងការជំរុញការអនុវត្តប្រកបដោយនិរន្តរភាពនៅក្នុងវិស័យកសិកម្ម។ ពីព្រោះតួនាទីគន្លឹះនៃហិរញ្ញវត្ថុនៅក្នុងការជំរុញការ វិនិយោគលើវិស័យកសិកម្ម គេមិនអាចប្រកែកបានទេថាការធានាការអនុវត្តត្រឹមត្រូវនៅក្នុងវិស័យហិរញ្ញវត្ថុកម្ពុជា នឹងផ្ដល់នូវការជំរុញដ៏ធំចំពោះដំណោះស្រាយប្រកបដោយជោគជ័យនូវវិវាទរវាងសហគ្រាសកសិធុរកិច្ច និងសហគមន៍មូលដ្ឋាន។

## ២ វិធីសាស្ត្រ

វិធីសាស្ត្រសម្រាប់ឯកសារគោលនយោបាយ និងរបាយការណ៍ស្រាវជ្រាវ រួមមានការសិក្សាឯកសារមានស្រាប់ និងការប្រមូលទិន្នន័យផ្ទាល់។

ការសិក្សាឯកសារមានស្រាប់ ត្រូវបានធ្វើជាដំបូងដើម្បីកំណត់ភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងចំណោមភាគីពាក់ព័ន្ធហិរញ្ញវត្ថុកម្ពុជា។ ភាគីពាក់ព័ន្ធទាំងនេះ ត្រូវបានកំណត់អត្តសញ្ញាណយោងតាមកម្រិតសន្មតនៃចំណេះដឹងអំពីការប្រតិបត្តិហិរញ្ញវត្ថុនៅក្នុងវិស័យកសិកម្ម និងឆន្ទៈរបស់ពួកគេក្នុងការចែករំលែកព័ត៌មានពាក់ព័ន្ធនៅក្នុងការសម្ភាសជាចុងក្រោយ។ ការវាយតម្លៃនេះ គឺផ្អែកលើការសន្មត ដែលកើតចេញពីបទពិសោធន៍ការងារមុនៗរបស់ក្រុមការងារស្រាវជ្រាវ ដែលថាភាគីពាក់ព័ន្ធខ្លះ ជាពិសេសធនាគារមិនចង់ចែករំលែកអ្វីដែលពួកគេចាត់ទុកថាជាព័ត៌មានរសើបទាក់ទិននឹងការផ្ដល់កម្ចី និងប្រតិបត្តិការហិរញ្ញវត្ថុផ្សេងទៀតរបស់ពួកគេ។ ហានិភ័យនេះ គឺជាហានិភ័យនៃការលំបាកនៃការសិក្សាដែលបានកំណត់ដោយក្រុមការងារស្រាវជ្រាវនៅក្នុងរបាយការណ៍ចាប់ផ្ដើម។

ការវាយតម្លៃនេះ បានផលិតបញ្ជីតូចមួយនៃបណ្ដាភាគីពាក់ព័ន្ធដែលត្រូវបានកំណត់អត្តសញ្ញាណសម្រាប់ការសម្ភាសន៍។ បន្ទាប់មក សំណួរត្រូវបានរៀបចំសម្រាប់ដំណាក់កាលប្រមូលទិន្នន័យ។ ចំណេះដឹងខ្លះៗដែលបានទទួលពីការសិក្សាឯកសារមានស្រាប់ ដូចជាចំណេះដឹងអំពីគំនិតផ្ដួចផ្ដើមហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពកម្ពុជា និងតួនាទីនាំមុខរបស់សមាគមធនាគារនៅកម្ពុជា (ABC) នៅក្នុងការជំរុញហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពនៅក្នុងប្រទេស ត្រូវបានប្រើដើម្បីផ្ដល់ព័ត៌មានដល់ការរៀបចំសំណួរ។ ដោយសារពេលវេលាមានកម្រិត សំណួរទាំងនេះត្រូវបានរៀបចំតាមវិធីមួយដែលចម្លើយនឹងគឺជាវិធីមួយសម្រាប់ផ្ទៀងផ្ទាត់របកគំហើញនៃការសិក្សាឯកសារមានស្រាប់ និងទទួលបានទិន្នន័យបែបគុណភាពថ្មី។

ដោយឡែក ការរំពឹងទុកពីការសម្ភាសន៍គឺការស្វែងយល់អំពីទស្សនៈផ្ទាល់នៃវិស័យហិរញ្ញវត្ថុអំពីគំនិតផ្ដួចផ្ដើមហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព និងកាលវិភាគប្រហាក់ប្រហែលសម្រាប់ដំណាក់

កាលកំណែទម្រង់អនាគត។ គួរឲ្យស្តាយ ការលំបាកនៃការសិក្សាដែលរំពឹងទុកបានលេចឡើងនៅក្នុងពេលសម្ភាសន៍ ពីព្រោះភាគីពាក់ព័ន្ធដែលផ្តល់សម្ភាសន៍មិនមានឆន្ទៈចែករំលែកព័ត៌មានលម្អិតជាច្រើនទាក់ទិននឹងសកម្មភាពផ្តល់កម្ចីនៃគ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជា។ ទោះបីជាមានការលំបាកទាំងនេះក្តី ក៏ទិន្នន័យបែបគុណភាពគ្រប់គ្រាន់ត្រូវបានប្រមូលដើម្បីផលិតរបាយការណ៍ស្រាវជ្រាវបែបនវានុវត្តន៍និងមានប្រយោជន៍មួយដែរ។

# ៣ របកគំហើញសំខាន់ៗ និងការវិភាគ

## ៣.១ សេចក្តីអធិប្បាយអំពីបញ្ហា

របកគំហើញគន្លឹះរបស់យើង គឺថាបច្ចុប្បន្នមានចំណុចខ្សោយនៅក្នុងលទ្ធភាពនៃវិស័យហិរញ្ញវត្ថុកម្ពុជាក្នុងការធានាថាសកម្មភាពរបស់ខ្លួនមាននិរន្តរភាព។ និរន្តរភាពនេះ មានន័យថាសកម្មភាពមិនបណ្តាលឲ្យមានបញ្ហាអវិជ្ជមានផ្នែកបរិស្ថាន សង្គម ឬអភិបាលកិច្ច (ESG) ដោយផ្ទាល់ឬដោយប្រយោលឡើយ។ ចំណុចខ្សោយទាំងនេះ ត្រូវបានឃើញច្បាស់នៅក្នុងបីទិដ្ឋភាព។

ទីមួយ អ្នកអនុវត្តហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធដទៃទៀត ខ្វះការយល់ដឹងនិងចំណេះដឹងអំពីទស្សនាទាន និងផលជះនៃហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព។ ដោយឡែក បុគ្គលិកដែលធ្វើការនៅតាមធនាគារកម្ពុជា និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត មិនសូវដឹងទេថាហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពកំពុងមានសម្ទុះក្នុងទូទាំងពិភពលោក ជាដំណោះស្រាយអភិវឌ្ឍន៍បែបនវានុវត្តន៍និងផ្តល់ផលចំណេញមួយ។ ចំណុចសំខាន់ គឺផ្តោតលើទំនាក់ទំនងរវាងការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងលទ្ធភាពចំណេញនៃធុរកិច្ចៈ មានករណីជាក់ស្តែងជាច្រើននៅក្នុងឯកសារនិពន្ធអំពីធនាគារអន្តរជាតិដែលបានចំណេញតាមវិធីមួយចំនួន ដោយបញ្ជ្រាបនិរន្តរភាពទៅក្នុងប្រតិបត្តិការ និងយុទ្ធសាស្ត្ររបស់ពួកគេ។ គំនិតផ្តួចផ្តើមក្នុងស្រុកមួយចំនួននៅកម្ពុជា ត្រូវបានជំរុញនិងអនុម័តយកដោយគ្រឹះស្ថានហិរញ្ញវត្ថុ ជាពិសេសតាមរយៈការងារនៃសមាគមចម្បងនៃវិស័យនេះ។ ទោះជាយ៉ាងណាក្តី ទិដ្ឋភាពទូទៅគឺថាហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពគឺស្ថិតនៅក្នុងដំណាក់កាលចាប់ផ្តើមនៅឡើយនៅក្នុងប្រទេស។

រីឯផ្នែកនិយ័តកម្ម ហាក់បីដូចជាមានគ្រឿងលើកទឹកចិត្តផ្នែកច្បាប់តិចតួចដើម្បីជំរុញឲ្យគ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជាកាន់តែមាននិរន្តរភាព។ សមិទ្ធផលដែលមាននៅក្នុងផ្នែកនេះ កន្លងមក គឺសម្រេចបានដោយសារការងារត្រួសត្រាយផ្លូវនៃសមាគមធនាគារនៅកម្ពុជា (ABC)។ សមាគមនេះអនុញ្ញាតឲ្យសមាជិកដែលមានឆន្ទៈនៃបណ្តាញធនាគារពួកគេ អនុលោមតាមវិធានការនិរន្តរភាពក្នុងកម្រិតមួយ ដែលផ្តោតគោលដៅឆ្ពោះទៅកាន់វិស័យហិរញ្ញវត្ថុកម្ពុជា។ ការអនុម័តយកវិធានការនេះជាសំខាន់ គឺមានលក្ខណៈដោយស្ម័គ្រចិត្ត។ ហេតុដូច្នេះ គេឃើញមានលំហរបើកទូលាយច្រើនសម្រាប់ឲ្យធនាគារមិនអនុលោមតាម និងទទួលរងផលវិបាកតិចតួច។ មានការជជែកអំពីកំណែទម្រង់អនាគតចំពោះក្របខ័ណ្ឌច្បាប់ ប៉ុន្តែនៅដំណាក់កាលនេះ ច្បាប់ពាក់ព័ន្ធនៅកំពុងត្រូវបានតាក់តែងនៅឡើយ ហើយខ្លឹមសារប្រាកដ និងផលប៉ះពាល់របស់វាលើវិស័យហិរញ្ញវត្ថុ គឺជាការស្មាន

សុទ្ធសាធ។

ជាចុងក្រោយ គ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជាមានល័ក្ខខ័ណ្ឌតម្រូវតិចតួចឲ្យអនុម័តយកវិធានការជំរុញតម្លាភាព ដូចជាការបញ្ចេញព័ត៌មានសមស្របស្តីពីរចនាសម្ព័ន្ធអភិបាលកិច្ច ភាពងាយរងគ្រោះផ្នែកប្រតិបត្តិការចំពោះហានិភ័យបរិស្ថាននិងសង្គម និងការអនុម័តយុទ្ធសាស្ត្រនិរន្តរភាព និង/ឬគោល នយោបាយ។ គ្រឹះស្ថានហិរញ្ញវត្ថុមួយចំនួននៅក្នុងប្រទេស ដូចបានលើកឡើងខាងលើ បានដើរតាមនិន្នាការដែលកំណត់ដោយ***គំនិតផ្តួចផ្តើមហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព*** និងបានចាប់ផ្តើមចុះផ្សាយរបាយការណ៍តាមអនឡាញ ដែលរាយលម្អិតគោលនយោបាយនិរន្តរភាព និងកិច្ចប្រឹងប្រែងរបស់ពួកគេក្នុងការជួយសហគមន៍មូលដ្ឋាន រួមទាំងទិន្នន័យបែបបរិមាណ។ ជាមួយហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពនៅក្នុងដំណាក់កាលចាប់ផ្តើម ចំណុចនេះគឺជានិន្នាការគួរឲ្យសង្ឃឹម និងគួរឲ្យកត់សម្គាល់។ ប៉ុន្តែកិច្ចប្រឹងប្រែងទាំងនេះមិនមានលក្ខណៈជាស្តង់ដារ ដោយរបាយការណ៍ខ្លះមានលក្ខណៈលម្អិតជាងរបាយការណ៍ដទៃ ហើយរបាយការណ៍ខ្លះហាក់បីដូចជាសេចក្តីថ្លែងចក្ខុវិស័យដ៏ទូលាយ។ គេក៏មិនដឹងច្បាស់ដែរថាតើកិច្ចប្រឹងប្រែងទាំងនេះឆ្លុះបញ្ចាំងអភិក្រមទូទាំងវិស័យចំពោះបញ្ហានេះជាជាងគំនិតផ្តួចផ្តើមលក្ខណៈបុគ្គល យ៉ាងដូចម្តេច។

## ៣.២ វិសាលភាពនៃអនុសាសន៍

ដោយបានកំណត់បញ្ហា យើងផ្តល់អនុសាសន៍លើបីវិស័យ៖ ការកសាងសមត្ថភាពនិយ័តកម្ម និង វិធានការជំរុញតម្លាភាព។ គោលបំណងនៃអនុសាសន៍ទាំងនេះ គឺសំដៅផ្តល់នូវឧបករណ៍ជាក់ស្តែងមួយសម្រាប់ការពិភាក្សាជាមួយភាគីពាក់ព័ន្ធនានា ជាពិសេស រាជរដ្ឋាភិបាលកម្ពុជា។ យើងសង្ឃឹមថាការពិភាក្សាអាចផ្តល់នូវកម្លាំងជំរុញមួយសម្រាប់ការអនុវត្តកំណែទម្រង់នៅក្នុងវិស័យនេះ ដោយរួមចំណែកដល់ការពិគ្រោះយោបល់ ក្នុងចំណោមភាគីពាក់ព័ន្ធដែលរងផលប៉ះពាល់នៅកម្ពុជា។ ដោយសំដៅធ្វើជាឧបករណ៍រួមមួយ អនុសាសន៍ទាំងនេះ មិនត្រឹមតែសំដៅលើរាជរដ្ឋាភិបាលកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងលើភាគីពាក់ព័ន្ធដទៃទៀត ដែលអាចរួមចំណែកដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការកែទម្រង់វិស័យហិរញ្ញវត្ថុទៀតផង។ តួអង្គទាំងនេះ រួមមានគ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជា និយ័តករ សមាគមតាមវិស័យ ដៃគូអភិវឌ្ឍន៍ និងសាធារណជនទូទៅ។

# ៤ អនុសាសន៍

## ៤.១ ការកសាងសមត្ថភាព

### ៤.១.១ សេចក្តីផ្តើម

គោលបំណងនៃអនុសាសន៍កសាងសមត្ថភាព គឺសំដៅបំពេញចន្លោះប្រហោងបច្ចុប្បន្នទាក់ទិននឹងចំណេះដឹងអំពីហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព ក្នុងចំណោមភាគីពាក់ព័ន្ធវិស័យហិរញ្ញវត្ថុកម្ពុជា។ ដូចបានលើកឡើងខាងលើ ចំណេះដឹងបច្ចុប្បន្នអាចកែលម្អបាន។ អនុសាសន៍ទាំងនេះ ផ្តោតជាពិសេសលើកម្លាំងការងារនៃគ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជា។ វិសាលភាព រាប់បញ្ចូលបុគ្គលិកគ្រប់

កម្រិតទាំងអស់ចាប់ពីបុគ្គលិកជួរមុខរហូតដល់ថ្នាក់គ្រប់គ្រងជាន់ខ្ពស់។ អនុសាសន៍ទាំងនេះក៏សំដៅផងដែរចំពោះរាជរដ្ឋាភិបាល និយ័តករនៃវិស័យហិរញ្ញវត្ថុ ដៃគូអភិវឌ្ឍន៍ និងតំណាងមកពីសមាគមតាមវិស័យ (ដូចជា សមាគមធនាគារនៅកម្ពុជា (ABC)) និងសមាគមអ្នកប្រើប្រាស់ជាដើម។

**ផលប៉ះពាល់លើកម្ពុជា**

ការអនុវត្តអនុសាសន៍ទាំងនេះប្រកបដោយជោគជ័យ នឹងបង្កើនចំណេះដឹង និងការយល់ដឹងអំពីហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព នៅកម្រិតមួយចំនួននៃសង្គមកម្ពុជា។

ជាសំខាន់ ធនាគារកម្ពុជា និងគ្រឹះស្ថានហិរញ្ញវត្ថុដទៃទៀត នឹងស្ថិតក្នុងស្ថានភាពល្អប្រសើរច្រើនដើម្បីរួមចំណែកយ៉ាងសកម្មដល់ការពង្រីកការប្រតិបត្តិហិរញ្ញវត្ថុល្អនៅក្នុងប្រទេស។ ជាក់ស្តែងចំណុចនេះនឹងមានន័យ ជាឧទាហរណ៍ ថាបុគ្គលិកជួរមុខទទួលបានការបណ្តុះបណ្តាល ដើម្បីដឹងកាន់តែប្រសើរឡើងអំពីហានិភ័យបរិស្ថាន និងសង្គមនៅពេលធ្វើប្រតិបត្តិការជាមួយអតិថិជន ឬថ្នាក់គ្រប់គ្រងជាន់ខ្ពស់ជំរុញការបង្កើតយុទ្ធសាស្ត្រនិរន្តរភាពបរិស្ថានថ្មីនិងលម្អិតជាងសម្រាប់ក្រុមហ៊ុនពួកគេ។

ប៉ុន្តែ មិនត្រឹមតែអ្នកធ្វើការនៅក្នុងចំណោមបុគ្គលិកហិរញ្ញវត្ថុទេដែលនឹងទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍនេះ។ រាជរដ្ឋាភិបាលកម្ពុជា និងនិយ័តករហិរញ្ញវត្ថុ នឹងដឹងកាន់តែច្រើនអំពីការអនុវត្តល្អពីនិយ័តករហិរញ្ញវត្ថុនៅប្រទេសដទៃ ដែលជួយឲ្យពួកគេអាចធ្វើសេចក្តីសម្រេចចិត្តប្រកបដោយព័ត៌មានកាន់តែពេញលេញ នៅពេលធ្វើកំណែទម្រង់គោលនយោបាយពាក់ព័ន្ធនៅកម្ពុជា។

ជាចុងក្រោយ សាធារណទូលំទូលាយ ដែលត្រូវបានតំណាងដោយអតិថិជននៃគ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជា នឹងយល់ដឹងកាន់តែច្រើនអំពីគំនិតផ្តួចផ្តើមនិរន្តរភាពសាជីវកម្ម និងគំនិតផ្តួចផ្តើមតាមវិស័យ ដែលត្រូវបានអនុវត្តដោយតួអង្គនៅកម្ពុជា ហើយដោយហេតុនេះ នឹងអាចធ្វើការជ្រើសរើសប្រើប្រាស់ប្រកបដោយព័ត៌មានកាន់តែពេញលេញ។ ឧទាហរណ៍ ដោយផ្តល់រង្វាន់ដល់ធនាគារដែលគិតគូរដល់និរន្តរភាព អ្នកខ្ចីកម្ពុជាលើកទឹកចិត្តឲ្យធនាគារកាន់តែច្រើនបោះជំហាននៅក្នុងទិសដៅនេះដូចគ្នា។

### ៤.១.២ វគ្គបណ្តុះបណ្តាល និងយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន

អនុសាសន៍ទាំងពីរ រួមមាន (១) រៀបចំវគ្គបណ្តុះបណ្តាល និង (២) អនុវត្តយុទ្ធនាការផ្សព្វផ្សាយព័ត៌មានអំពីទិដ្ឋភាពនៃហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព។ គំនិតផ្តួចផ្តើមទាំងពីរនេះ រួមមានការរៀបចំកម្មវិធីសិក្សាបែបផ្តល់ព័ត៌មាន ដែលត្រូវបានសម្រួលទៅតាមតម្រូវការផ្សេងៗរបស់ភាគីពាក់ព័ន្ធដែលកម្មវិធីសិក្សាផ្តោតលើ។

ដោយសារវិសាលភាពនៃការងារ បុគ្គលិកគ្រឹះស្ថានហិរញ្ញវត្ថុ និងនិយ័តករហិរញ្ញវត្ថុ ពាក់ព័ន្ធនៅក្នុងហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពច្រើនជាងភាគីពាក់ព័ន្ធដទៃទៀត ដូចជាសមាគមអ្នកប្រើប្រាស់ជាដើម។ ហេតុដូច្នេះ សម្ភារៈបណ្តុះបណ្តាល និងសម្ភារៈផ្សព្វផ្សាយ ដែលត្រូវបានរៀបចំសម្រាប់វិស័យហិរញ្ញ

វត្ថុឯកជន និងនិយ័តករហិរញ្ញវត្ថុ នឹងមានលក្ខណៈស៊ីជម្រៅ និងគ្របដណ្តប់ទិដ្ឋភាពបច្ចេកទេសនៃហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពច្រើនជាងសម្ភារៈបណ្តុះបណ្តាល និងសម្ភារៈផ្សព្វផ្សាយសម្រាប់តួអង្គផ្សេងទៀត។ ព័ត៌មានណែនាំ អាចដាក់បញ្ចូលជាអាទិ៍ ការពន្យល់អំពីនិយមន័យនិងទស្សនទានគន្លឹះនានា និងទស្សនៈរួមមួយស្តីពីឧត្តមានុវត្តជាអន្តរជាតិ។ ប្រធានបទសំខាន់ៗ រួមមានអំណះអំណាងធុរកិច្ចដើម្បីនិរន្តរភាព និង ការផ្តល់ឧទហរណ៍នៃក្របខ័ណ្ឌនិយ័តកម្ម ដែលបង្កើតដោយរដ្ឋាភិបាល និងនិយ័តករក្នុងទូទាំងពិភពលោក។ ក្នុងឋានៈជាតួអង្គនាំមុខចម្បងនៃការផ្លាស់ប្តូរនៅក្នុងហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព វាគឺជាប្រការសំខាន់ដែលវិស័យឯកជនក្តាប់យកអត្ថប្រយោជន៍ នៃ "ការអនុវត្តបៃតង" ហើយសម្ភារៈផ្តល់ព័ត៌មានគប្បីផ្តល់ឧទាហរណ៍ច្រើនអំពីអត្ថប្រយោជន៍បែបនេះដែលគ្រឹះស្ថានហិរញ្ញវត្ថុបានទទួល ដូចជាកេរ្តិ៍ឈ្មោះស្លាកយីហោកាន់តែប្រសើរឡើង និងលទ្ធភាពទទួលបានប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាប។

ផ្ទុយទៅវិញ សម្ភារៈដែលរៀបចំសម្រាប់ភាគីពាក់ព័ន្ធដទៃទៀត នឹងមានលក្ខណៈស្រាលជាង និងបច្ចេកទេសតិចជាង ដោយផ្តោតច្រើនជាងលើការពន្យល់ពីរបៀបដែលភាគីពាក់ព័ន្ធមិនមែនហិរញ្ញវត្ថុអាចរួមចំណែកដល់ការធ្វើឲ្យវិស័យនេះកាន់តែមាននិរន្តរភាព ដូចជាដោយរៀបចំវេទិកាពាក់ព័ន្ធពហុភាគីពាក់ព័ន្ធ និងឯកភាពគ្នាលើផែនការសកម្មភាពរួម។

ដូចមានលើកឡើងនៅក្នុងរបាយការណ៍ស្រាវជ្រាវ មានឯកសារនិពន្ធជាច្រើនដែលបង្ហាញលម្អិតនូវឧត្តមានុវត្តហិរញ្ញវត្ថុសម្រាប់ប្រើជាទុន នៅពេលរៀបចំកម្មវិធីបណ្តុះបណ្តាល និងកម្មវិធីសិក្សាបែបផ្តល់ព័ត៌មាន។

## ៤.២ និយ័តកម្ម

### ៤.២.១ សេចក្តីផ្តើម

គោលបំណងនៃអនុសាសន៍និយ័តកម្ម គឺសំដៅផ្តល់លំហរមួយសម្រាប់កំណែទម្រង់ហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពជាប្រចាំ ដែលពង្រឹងតួនាទីរបស់រដ្ឋាភិបាល និងនិយ័តករផ្សេងៗទៀត នៅក្នុងការជំរុញឧត្តមានុវត្តហិរញ្ញវត្ថុ។ ថ្វីបើរាជរដ្ឋាភិបាលកម្ពុជាបានគាំទ្រ *គំនិតផ្តួចផ្តើមហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព* ដោយក្រសួងបរិស្ថានបានយល់ព្រមលើគំនិតផ្តួចផ្តើមនេះក្តី ក៏ក្របខ័ណ្ឌនិយ័តកម្មហិរញ្ញវត្ថុបច្ចុប្បន្ននៅកម្ពុជា ហាក់បីដូចជាមិនមានលក្ខណៈតឹងរ៉ឹងខ្លាំងក្នុងការតម្រូវឲ្យគ្រឹះស្ថានហិរញ្ញវត្ថុដាក់បញ្ចូលនិរន្តរភាពនៅក្នុងយុទ្ធសាស្ត្រនិងកិច្ចប្រតិបត្តិការពួកគេទេ។

មកដល់ពេលនេះ កម្លាំងជំរុញដើម្បីការផ្លាស់ប្តូរត្រូវបានផ្តល់ដោយគំនិតផ្តួចផ្តើមស្វយ័តរបស់សមាគមវិស័យដ៏សំខាន់នៃកម្ពុជា ពោលគឺសមាគមធនាគារនៅកម្ពុជា (ABC)។ ការជំរុញហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព បច្ចុប្បន្នពឹងផ្អែកភាគច្រើនលើការចូលរួមដោយស្ម័គ្រចិត្តរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ជាមួយគ្រឿងលើកទឹកចិត្តផ្លូវច្បាប់តិចតួចសម្រាប់ឲ្យគ្រឹះស្ថានហិរញ្ញវត្ថុដែលមិនចូលរួមគោរពអនុវត្ត។ ហេតុដូច្នេះ ក្របខ័ណ្ឌនិយ័តកម្មអាចត្រូវបានពង្រឹងដោយដាក់ឲ្យអនុវត្តនូវល័ក្ខខ័ណ្ឌតម្រូវសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ពាក់ព័ន្ធនឹងនិរន្តរភាព និងបង្កើតយុទ្ធសាស្ត្រវិស័យរួមមួយ ដែលមានតួ

នាទីនិងល័ក្ខខ័ណ្ឌតម្រូវច្បាស់លាស់កំណត់ឲ្យរាល់ភាគីពាក់ព័ន្ធនីមួយៗនៅកម្ពុជា ចាប់ពីគ្រឹះស្ថានហិរញ្ញវត្ថុរហូតដល់សមាគមតាមវិស័យ និងនិយ័តករជាតិ។ ជាកិច្ចប្រឹងប្រែងសមូហភាពមួយ អនុសាសន៍ទាំងនេះគឺសំដៅជាបឋមលើគ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជា រាជរដ្ឋាភិបាល និងសមាគមតាមវិស័យ

**ផលប៉ះពាល់លើកម្ពុជា**

ក្របខ័ណ្ឌនិយ័តកម្មហិរញ្ញវត្ថុកាន់តែតឹងរ៉ឹងមួយ ត្រូវបានរំពឹងថានឹងបង្កើនអនុលោមភាពដោយគ្រឹះស្ថានហិរញ្ញវត្ថុ ទាក់ទិននឹងការដាក់បញ្ចូលនិរន្តរភាពទៅក្នុងយុទ្ធសាស្ត្រនិងកិច្ចប្រតិបត្តិការរបស់សាជីវកម្ម។

លើសពីនេះ ការបង្កើតយុទ្ធសាស្ត្រជាតិទូទាំងវិស័យត្រូវបានរំពឹងថានឹងបង្កើនការចូលរួមរបស់ភាគីពាក់ព័ន្ធសំខាន់ៗទាំងអស់ក្នុងការជំរុញហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពនៅកម្ពុជា។

សមាសភាគនៃយុទ្ធសាស្ត្រនេះ អាចគឺជាកាបង្កើតនិងការផ្តល់ភាពស្របច្បាប់ដល់វេទិកាពហុភាគីពាក់ព័ន្ធសម្រាប់ការសន្ទនា និងការចូលរួមពីគ្រប់វិស័យពាក់ព័ន្ធទាំងអស់នៃសង្គមកម្ពុជា។ វេទិកានេះនឹងផ្តល់នូវកន្លែងមួយសម្រាប់ឲ្យតួអង្គកម្ពុជាមិនសូវពេញចិត្តនានា ដូចជាសមាជិកនៃអង្គការសង្គមស៊ីវិលជាដើម អាចផ្តល់ឱវាទរបស់ពួកគេអំពីរបៀបកាត់បន្ថយហានិភ័យផ្នែកបរិស្ថាននិងសង្គមខ្លះៗដែលចេញមកពីការប្រតិបត្តិហិរញ្ញវត្ថុបច្ចុប្បន្ននៅក្នុងប្រទេស។ ប្រសិនបើត្រូវបានធ្វើក្នុងលក្ខណៈស្ថាបនា ការពាក់ព័ន្ធនិងការសន្ទនាអន្តរវិស័យត្រូវបានរំពឹងថានឹងកសាងទំនុកចិត្ត និងប្រកប្រាស្រ័យទាក់ទងរវាងក្រុមមានចំណាប់អារម្មណ៍ផ្សេងៗ។

### ៤.២.២ បង្កើតយុទ្ធសាស្ត្រវិស័យមួយ និងវេទិកាចូលរួម

ជំហានទីមួយដើម្បីបំភ្លឺក្របខ័ណ្ឌនិយ័តកម្មកម្ពុជាគឺការបង្កើតយុទ្ធសាស្ត្រវិស័យទូទាំងប្រទេសដែលបែងចែកតួនាទីនិងភារកិច្ចច្បាស់លាស់សម្រាប់ភាគីពាក់ព័ន្ធនីមួយៗនៃវិស័យហិរញ្ញវត្ថុ។ ខ្លឹមសារនៃយុទ្ធសាស្ត្រនេះ អាចត្រូវពិភាក្សានាពេលអនាគត ប៉ុន្តែវាគប្បីដាក់បញ្ចូលសេចក្តីថ្លែងចក្ខុវិស័យ ផែនទីភាគីពាក់ព័ន្ធ និង ផែនទីបង្ហាញផ្លូវ ជាមួយកាលវិភាគសកម្មភាពពេញលេញ។

កិច្ចដំណើរការនេះ នឹងរួមមានការពិគ្រោះយោបល់ពហុភាគីពាក់ព័ន្ធជាបន្តបន្ទាប់ និងជំនួយរបស់ជំនាញការវិស័យ ដែលនឹងបង្ហាញឧត្តមានុវត្តជាអន្តរជាតិខ្លះៗពាក់ព័ន្ធការងារនេះ និងជួយណែនាំការរៀបចំយុទ្ធសាស្ត្រនេះ។

ការពិគ្រោះយោបល់ អាចត្រូវបានប្រែក្លាយជាផ្លូវការទៅជាវេទិកាសន្ទនានិងចូលរួមថ្នាក់ជាតិមួយ ដែលអាចជួបប្រជុំទៀងទាត់ដើម្បីផ្តល់ការពិភាក្សាជាប្រចាំ ស្តីពីទិដ្ឋភាពនានាទាក់ទិននឹងការអនុវត្តហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពនៅកម្ពុជា។

គោលការណ៍ណែនាំដំបូង អាចជួយដឹកនាំកិច្ចដំណើរការពិគ្រោះយោបល់។ គោលការណ៍ណែនាំទាំងនេះ អាចរួមមានៈ ការកំណត់វិស័យឯកជនជាកត្តានាំមុខចម្បងនៃការជំរុញហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពនៅកម្ពុជា ការកំណត់សមាគមធនាគារនៅកម្ពុជា (ABC) ជាស្ថាប័នសម្របសម្រួលចម្បងនៃគំនិតផ្តួចផ្តើមហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព ការចាត់តួនាទីត្រួតពិនិត្យទៅឲ្យ

ធនាគារជាតិនៃកម្ពុជា និង តួនាទីនិយ័តកម្មទៅឲ្យក្រសួងសាមីពាក់ព័ន្ធ និង ការកសាងមូលដ្ឋានសម្រាប់បណ្ដាញចូលរួម "កម្រិតមូលដ្ឋាន" ពីសាធារណជនទូលាយ រួមទាំងអង្គការសង្គមស៊ីវិល និងសមាគមអ្នកប្រើប្រាស់។ គោលការណ៍ណែនាំទាំងនេះ អាចបោះពុម្ពផ្សាយជាឯកសារមួយ និង ផ្សព្វផ្សាយនៅក្នុងចំណោមភាគីពាក់ព័ន្ធមុនពេលពិគ្រោះយោបល់។

### ៤.២.៣ បង្កើតឧបករណ៍ដើម្បីគ្រប់គ្រងអនុលោមភាព និងការសន្ទនាភាគីពាក់ព័ន្ធ

ឧបករណ៍ពីរអាចត្រូវបានបង្កើតឡើងដើម្បីកែលម្អប្រសិទ្ធភាពនៃការផ្លាស់ប្ដូរផ្នែកនិយ័តកម្ម៖ ការបង្កើតប្រព័ន្ធដាក់ពិន័យមួយសម្រាប់អ្នកមិនអនុលោមតាម និងយន្តការមួយដើម្បីដោះស្រាយបណ្ដឹងតវ៉ាពីសង្គមកម្ពុជា។

ប្រព័ន្ធដាក់ពិន័យ អាចរួមមានការដាក់ពិន័យកម្រិតផ្សេងៗ ដោយផ្អែកលើភាពធ្ងន់ធ្ងរនៃបទល្មើស។ ឧទាហរណ៍ ជនល្មើសស្រាលអាចរួមមាន ជាឧទាហរណ៍ របាយការណ៍តាមដានត្រួតពិនិត្យដោយភាគីទីបី ឬ ត្រូវចេញលិខិតព្រមានមួយ ខណៈដែលជនល្មើសធ្ងន់ជាងអាចត្រូវបានគំរាមជាមួយការដកចេញពីសមាគមធនាគារនៅកម្ពុជា (ABC) ឬស្ថាប័នវិស័យពាក់ព័ន្ធផ្សេងទៀតដែលជនល្មើសនោះជាសមាជិក។

ឧបករណ៍ទីពីរ គឺជាយន្តការតាមដានត្រួតពិនិត្យមួយដើម្បីដោះស្រាយបណ្ដឹងតវ៉ាពីសង្គមកម្ពុជាទាក់ទិននឹងការអនុវត្តការប្រតិបត្តិហិរញ្ញវត្ថុនៅក្នុងប្រទេស។ ការស្ដាប់ឮ និងការព្យាយាមដោះស្រាយបណ្ដឹងតវ៉ាបែបនេះ នឹងជួយដល់ការកសាងទំនុកចិត្តពីសំណាក់ក្រុមអ្នកមិនសូវសប្បាយចិត្តនៃសង្គមកម្ពុជា។ រចនាសម្ព័ន្ធជាក់ស្ដែងនៃយន្តការ នឹងត្រូវកំណត់នៅពេលក្រោយ។ ប៉ុន្តែ ដូចក្នុងករណីដទៃទៀតដែរ គេឃើញមានសម្ភារៈព័ត៌មានជាច្រើនស្ដីពីយន្តការដូចគ្នា ដែលមានអត្ថិភាពរួច ហើយក្នុងទូទាំងពិភពលោក ដូចជាការិយាល័យទទួលបណ្ដឹងប្រជាពលរដ្ឋ (civil ombudsmen) ជាដើម។

## ៤.៣ ការតាមដាន និងការបញ្ចេញព័ត៌មាន

### ៤.៣.១ សេចក្ដីផ្ដើម

គោលបំណងនៃអនុសាសន៍ចុងក្រោយនេះ គឺសំដៅតភ្ជាប់គម្លាតតម្លាភាពបច្ចុប្បន្នដែលមានទាក់ទិននឹងការបញ្ចេញព័ត៌មានអំពីសកម្មភាពប្រកបដោយនិរន្តរភាព រួមមានការអនុម័តយកយុទ្ធសាស្ត្រនិរន្តរភាពសាជីវកម្ម និងគំនិតផ្ដួចផ្ដើមកំពុងដំណើរការ ដោយគ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជា។

បច្ចុប្បន្ន ដូចបានលើកឡើងខាងលើ ក្របខ័ណ្ឌនិយ័តកម្មមិនមានលក្ខណៈតឹងរ៉ឹង ទាក់ទិននឹងល័ក្ខ ខ័ណ្ឌតម្រូវសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុក្នុងការអនុវត្តការប្រតិបត្តិប្រកបដោយនិរន្តរភាព។ ចំណុចមួយចំនួនដែលមានតិចតួចឬមិនមានល័ក្ខខ័ណ្ឌតម្រូវផ្នែកនិយ័តកម្ម រួមមានការបញ្ចេញព័ត៌មានដោយខ្លួនឯងរបស់គ្រឹះស្ថានហិរញ្ញវត្ថុអំពីសកម្មភាព និងយុទ្ធសាស្ត្រប្រកបដោយនិរន្តរភាព, គោលនយោបាយបរិស្ថាននិងសង្គម និងរចនាសម្ព័ន្ធអភិបាលកិច្ច និងភាពងាយរងគ្រោះផ្នែកប្រតិបត្តិការចំពោះហានិភ័យបរិស្ថាននិងសង្គម។ ក្នុងបរិបទនេះ គ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជា មិនសូវមានគ្រឿងលើកទឹកចិត្តផ្នែកច្បាប់ដើម្បីផ្ដល់ព័ត៌មានជូនសាធារណជន ឧទាហរណ៍ ដោយចុះផ្សាយដោយឥតគិតថ្លៃនូវរបាយការណ៍និរន្តរភាពដែលមាននៅលើគេហទំព័ររបស់ពួកគេទេ។ នៅពេល

ដែលព័ត៌មានបែបនេះត្រូវបានបញ្ចេញ កិច្ចដំណើរការគឺពឹងផ្អែកលើការប្រកាន់ខ្ជាប់ដោយស្ម័គ្រចិត្តនូវការប្រតិបត្តិចែករំលែកព័ត៌មានប្រកបដោយតម្លាភាពដោយគ្រឹះស្ថាននៅក្នុងប្រទេស។

ដោយសារសមាសភាគគន្លឹះមួយនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងជាក់ស្តែងហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព ត្រូវរាប់បញ្ចូលភាគីពាក់ព័ន្ធផ្សេងៗច្រើននៅក្នុងការតាមដានត្រួតពិនិត្យសកម្មភាពក្រុមហ៊ុន វានឹងគឺជាប្រការមានប្រយោជន៍ក្នុងន័យនេះដែលត្រូវផ្តល់គ្រឿងលើកទឹកចិត្តរឹងមាំជាងសម្រាប់ឲ្យគ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជាបញ្ចេញព័ត៌មានសមស្របជូនសាធារណជន។

**ផលប៉ះពាល់លើកម្ពុជា**

ការអនុវត្តអនុសាសន៍តាមដានត្រួតពិនិត្យ និងបញ្ចេញព័ត៌មាន ត្រូវបានរំពឹងថានឹងកាត់បន្ថយយ៉ាងច្រើននូវគម្លាតតម្លាភាពដែលបានលើកឡើង ដោយធានានូវអត្ថប្រយោជន៍ដ៏ទូលាយចំពោះសង្គមកម្ពុជា។ អត្ថប្រយោជន៍ទាំងនេះ រួមមានការកសាងទំនុកចិត្តក្នុងចំណោមភាគីពាក់ព័ន្ធហិរញ្ញវត្ថុ និង កំណើនសមត្ថភាពសម្រាប់ភាគីពាក់ព័ន្ធដែលរងផលប៉ះពាល់ ដូចជារាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងសមាគមអ្នកប្រើប្រាស់ ដើម្បីតាមដានត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពនូវកិច្ចប្រតិបត្តិការដោយគ្រឹះស្ថានហិរញ្ញវត្ថុ និងការកំណត់ចំណុចខ្សោយនានានៅក្នុងការអនុវត្តសាជីវកម្មនូវការប្រតិបត្តិប្រកបដោយនិរន្តរភាព។

ដោយផ្សព្វផ្សាយព័ត៌មានយ៉ាងច្បាស់លាស់ជូនអ្នកណាដែលចាប់អារម្មណ៍ចង់មើល គ្រឹះស្ថានហិរញ្ញវត្ថុអាចបង្ហាញសុឆន្ទៈរបស់ខ្លួនចំពោះសាធារណជនកម្ពុជា ជាពិសេសចំពោះក្រុមមានចំណាប់អារម្មណ៍ ដែលបច្ចុប្បន្នយល់ថាពួកគេត្រូវបានគេមើលរំលងនៅក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ ជាថ្នូរមកវិញ គ្រឹះស្ថានហិរញ្ញវត្ថុដែលអនុលោមតាមអាចរំពឹងថានឹងទទួលបានផលចំណេញជាច្រើន ទាក់ទិននឹងកេរ្តិ៍ឈ្មោះរបស់ពួកគេចំពោះសាធារណជនកម្ពុជា និងសហគមន៍អភិវឌ្ឍន៍អន្តរជាតិ។

ព័ត៌មានដែលដាក់បង្ហាញ អាចជួយអ្នកដែលចាប់អារម្មណ៍លើការតាមដានអនុលោមភាពសាជីវកម្មជាមួយល័ក្ខខ័ណ្ឌតម្រូវនិរន្តរភាព ដោយផ្តល់ជូនពួកគេនូវការដឹងលម្អិតកាន់តែច្រើនអំពីកិច្ចប្រឹងប្រែងដោយគ្រឹះស្ថាននីមួយៗនៅក្នុងវិស័យនេះ។ បន្ទាប់មក ទិន្នន័យអាចត្រូវបានបកស្រាយទៅជាឧបករណ៍វាស់វែងនានា ដូចជា គំនូសផែនទីកំណត់ភាគីពាក់ព័ន្ធ ការវាយតម្លៃសាជីវកម្មតាមស្តង់ដារ និង សូចនាករសមិទ្ធកម្ម។

លទ្ធផលនៃទំនុកចិត្តកាន់តែច្រើននៅក្នុងចំណោមភាគីពាក់ព័ន្ធ ត្រូវបានធានាដើម្បីកសាងសម្ទុះថែមទៀតដើម្បីកំណែទម្រង់នៅក្នុងវិស័យនេះ ដោយលុបបំបាត់ឧបសគ្គចំពោះកិច្ចសហប្រតិបត្តិការភាគីពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព និង ដោយបង្កើនល្បឿននៃការប្រសព្វផលប្រយោជន៍។ កិច្ចដំណើរការនេះ នឹងធានាបាននូវផលប៉ះពាល់វិជ្ជមានយូរអង្វែង ដែលមានឥទ្ធិពលលើសពីទិដ្ឋភាពនិយ័តកម្មទៅទៀត ដែលធ្វើឲ្យកំណែទម្រង់ហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពក្លាយជាសមាសភាគគន្លឹះមួយនៃការអភិវឌ្ឍកម្ពុជានាពេលអនាគត។

### ៤.៣.២ គ្រឹះស្ថានហិរញ្ញវត្ថុរាយការណ៍អំពីយុទ្ធសាស្រ្តនិរន្តរភាព

អនុសាសន៍ទីមួយ គឺការកំណត់តម្រូវឲ្យគ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជាបញ្ចេញព័ត៌មានស្តីពីយុទ្ធសាស្រ្តនិរន្តរភាព ភាពងាយរងគ្រោះផ្នែកប្រតិបត្តិការចំពោះហានិភ័យផ្នែកបរិស្ថាននិងសង្គម និងវិស័យសាជីវកម្មផ្សេងទៀតរបស់ពួកគេ ដូចជារចនាសម្ព័ន្ធអភិបាលកិច្ចជាដើម ដែលគឺជាការចាប់អារម្មណ៍ចំពោះសាធារណជនដើម្បីគោលបំណងតាមដានត្រួតពិនិត្យ។ ថ្វីបើក្រុមហ៊ុនខ្លះនៅកម្ពុជាមាន លក្ខណៈសកម្មរួចហើយក្នុងការចែករំលែកព័ត៌មាននេះដូចបានលើកឡើងខាងដើមក្តី ក៏ការតាំងចិត្តនេះមានលក្ខណៈស្ម័គ្រចិត្តទាំងស្រុងដែរ។

ដូចគ្នានឹងល័ក្ខខ័ណ្ឌតម្រូវឲ្យគ្រឹះស្ថានហិរញ្ញវត្ថុអនុម័តយុទ្ធសាស្រ្តនិរន្តរភាពមួយដែរ ការដាក់ឲ្យអនុវត្តល័ក្ខខ័ណ្ឌតម្រូវផ្លូវច្បាប់ក្នុងន័យនេះនឹងបង្កើនអនុលោមភាពក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជា។ តាមវិធីដូចគ្នានេះដែរ ប្រព័ន្ធពិន័យតាមលំដាប់មួយអាចត្រូវបានដាក់ឲ្យអនុវត្តសម្រាប់អ្នកមិនអនុលោមតាម ដែលមានតាំងពីការព្រមានរហូតដល់ការដាក់ទណ្ឌកម្ម។ ទន្ទឹមនឹងនេះ ក្រុមហ៊ុនដែលអនុលោមតាមអាចត្រូវបានផ្តល់រង្វាន់តាមរយៈកេរ្តិ៍ឈ្មោះកាន់តែល្បី និងការទទួលស្គាល់ពីនិយ័តករមានសមត្ថកិច្ច។

### ៤.៣.៣ ផ្តល់ទម្រង់គំរូរួមសម្រាប់ការរាយការណ៍

អនុសាសន៍ទីពីរ សំដៅផ្តល់ជូនគ្រឹះស្ថានហិរញ្ញវត្ថុនូវទម្រង់គំរូរួមសម្រាប់ល័ក្ខខ័ណ្ឌតម្រូវរាយការណ៍របស់ពួកគេដែលបានលើកឡើងខាងលើ។ ទម្រង់គំរូទាំងនេះ នឹងត្រូវបានផ្សព្វផ្សាយនៅក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធហិរញ្ញវត្ថុផ្សេងទៀត ហើយការអនុម័តយកទម្រង់គំរូទាំងនេះអាចគឺជាប្រធានបទនៃវគ្គបណ្តុះបណ្តាលមួយដែលផ្តល់ជូនគ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជាដែលអនុលោមតាម។

ការធ្វើស្តង់ដារនីយកម្មឯកសាររាយការណ៍ នឹងជួយកាត់បន្ថយថ្លៃចំណាយប្រតិបត្តិការសម្រាប់អ្នកដែលអនុលោមតាម ពោលគឺគ្រឹះស្ថានហិរញ្ញវត្ថុ និងអ្នកដែលទទួលបន្ទុកតាមដានរបាយការណ៍ទាំងនេះ។ ក្នុងករណីទីមួយ គ្រឹះស្ថានហិរញ្ញវត្ថុនឹងកាត់បន្ថយពេលវេលា និងថ្លៃចំណាយសម្រាប់ការសរសេររបាយការណ៍បែបនេះ ដោយការមានគោលការណ៍ណែនាំច្បាស់លាស់ និងដោយត្រូវបានបង្ហាញយ៉ាងប្រាកដនូវប្រភេទព័ត៌មានដែលត្រូវបានតម្រូវសម្រាប់ពួកគេជាមុន។ ក្នុងករណីទីពីរ ភាគីពាក់ព័ន្ធដែលតាមដាន អាចប្រើរបាយការណ៍ជាស្តង់ដារទាំងនេះ ដើម្បីធ្វើសេចក្តីសម្រេចចិត្តប្រកបដោយព័ត៌មានពេញលេញ និងអាចឈានដល់ការផ្តល់គំរូរង្វាស់ស្តង់ដារទាក់ទិននឹងកម្រិតនៃអនុលោមភាពដោយគ្រឹះស្ថានហិរញ្ញវត្ថុទៀតផង។

គេឃើញមានឯកសារជាច្រើនទាក់ទិននឹងការអនុម័តយកទម្រង់គំរូរួមដោយភាគីពាក់ព័ន្ធហិរញ្ញវត្ថុអន្តរជាតិ ដែលឯកសារទាំងនោះមួយចំនួនត្រូវបានបង្ហាញលម្អិតនៅក្នុងរបាយការណ៍ស្រាវជ្រាវ។ ឯកសារនេះ អាចជួយផ្តល់ព័ត៌មានដល់ការជ្រើសរើសទម្រង់គំរូបែបនេះសម្រាប់វិស័យហិរញ្ញវត្ថុកម្ពុជា។